មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
CCIM
cambodian center for independent media

ខេមបូចា CamboJA

OPC Cambodia

# សេចក្តីថ្លែងការណ៍រួម៖ អ្នកសារព័ត៌មាន វីអូឌី និង វីអូអេ ត្រូវបានបដិសេធមិនឱ្យចូលរួមក្នុងសន្និសីទសារព័ត៌មានរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ — យើង ជាស្ថាប័នសារព័ត៌មានដែលមានរាយឈ្មោះដូចខាងក្រោម សូមធ្វើការអំពាវនាវដល់ក្រសួងព័ត៌មានឱ្យបំភ្លឺអំពីមូលហេតុដែលអ្នកសារព័ត៌មានព័ត៌មាន វីអូឌី (VOD) និងវីអូអេ (VOA) ត្រូវបានបដិសេធមិនឱ្យចូលទៅក្នុងសន្និសីទសារព័ត៌មានមួយរបស់រដ្ឋាភិបាលក្រោមវត្តមានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃអាទិត្យ ទី១៣ ខែវិច្ឆិកា ស្របពេលដែលអ្នកសារព័ត៌មានរាប់សិបនាក់ផ្សេងទៀតត្រូវបានអនុញ្ញាតឱ្យចូល។

កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២២នេះ អ្នកសារព័ត៌មានវីអូឌីនិងវីអូអេ បានចុះឈ្មោះដើម្បីយកព័ត៌មានក្រោយកិច្ចប្រជុំកំពូលអាស៊ាន នៅឯវិមានសន្តិភាពក្នុងរាជធានីភ្នំពេញ។ សារព័ត៌មានវីអូឌីនិងវីអូអេគឺស្ថិតនៅក្នុងចំណោមស្ថាប័នប្រព័ន្ធផ្សព្វផ្សាយចំនួន១០ដែលបានចុះឈ្មោះដំបូងគេ ហើយអ្នកសារព័ត៌មានវីអូឌីនិងវីអូអេក៏មានបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មានផងដែរ។

ទោះជាយ៉ាងណា នៅវេលាម៉ោងប្រមាណជា ១ និង៤៥នាទីរសៀល ពោលគឺនៅមុនពេលផ្តល់បណ្ណអនុញ្ញាតសម្រាប់ចូលក្នុងសន្និសីទដល់ប្រព័ន្ធផ្សព្វផ្សាយដែលបានចុះឈ្មោះ មន្ត្រីផ្នែកព័ត៌មានរបស់ក្រសួងព័ត៌មានចំនួនពីររូបបានប្រាប់អ្នកសារព័ត៌មានវីអូឌីថា ថ្នាក់លើរបស់ពួកគេមិនអនុញ្ញាតឱ្យអ្នកសារព័ត៌មានវីអូឌីនិងវីអូអេចូលរួមក្នុងសន្និសីទសារព័ត៌មានរបស់លោក ហ៊ុន សែន ឡើយ។

ទាក់ទិននឹងករណីនេះ អ្នកសារព័ត៌មានក៏បានស្នើសុំហេតុផលដែលពួកគេត្រូវបានបដិសេធមិនឱ្យចូលរួមក្នុងសន្និសីទកាសែតខាងលើនេះផងដែរ ប៉ុន្តែមិនទទួលបានចម្លើយនោះទេ បើទោះបីជាពួកគេបានទាក់ទងទៅកាន់មន្ត្រីជាន់ខ្ពស់មួយរូបរបស់ក្រសួងដើម្បីសាកសួរក៏ដោយ។
ជាមួយគ្នានេះ អ្នកកាសែតវីអូអេក៏បានទៅកាន់ទីតាំងប្រព័ន្ធផ្សព្វផ្សាយនៃកិច្ចប្រជុំកំពូលដើម្បីស្នើសុំបណ្ណអនុញ្ញាតតែក៏ត្រូវបានបដិសេធផងដែរ។

យើងសូមធ្វើការអំពាវនាវដល់ក្រសួងឱ្យពន្យល់ពីករណីរើសអើងដែលកើតឡើងជាក់ស្តែងនេះចំពោះអ្នកសារព័ត៌មានមកពីស្ថាប័នព័ត៌មានមួយចំនួន។ យើងយល់ឃើញថា វាគ្មានហេតុផលសមស្របណាមួយក្នុងការបដិសេធអ្នកសារព័ត៌មានអាជីពពីការចូលទៅរាយការណ៍ព័ត៌មានដើម្បីប្រើប្រាស់ជាប្រយោជន៍សាធារណៈនោះទេ។ ស្របពេលដែលលោកនាយករដ្ឋមន្ត្រីមានការស្វាគមន៍នូវរាល់សំណួរពីប្រព័ន្ធផ្សព្វផ្សាយនានា យើងចង់ដឹងថាហេតុអ្វីបានជាអ្នកសារព័ត៌មានរបស់វីអូឌី និងវីអូអេមិនត្រូវបានស្វាគមន៍ក្នុងការសួរសំណួរទៅវិញ៕

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

អ្នកស្រី ឆន សុគន្ធា នាយិកានាយកដ្ឋានអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) តាមរយៈទូរសព្ទឬបណ្តាញ Signal លេខ (+៨៥៥) ៧៨២២៤៦៦ ឬតាមរយៈអ៊ីមែល csokunthea@ccimcambodia.org (ភាសាអង់គ្លេសនិងភាសារខ្មែរ)

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) តាមរយៈទូរសព្ទឬបណ្តាញ Signal លេខ (+៨៥៥) ១២៥១៩២៦១ ឬតាមរយៈអ៊ីមែល ed@camboja.net (ភាសាអង់គ្លេសនិងភាសាខ្មែរ)

សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖

១. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM)

២. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)

៣. ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)